ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៦៤ ប្រក. កសក

# ប្រកាស
# ស្តីពី
# ការបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម ខេត្តព្រះសីហនុ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គ-នាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ៥៣ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៦ ស្តីពីការធ្វើពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលកំពុងរងគ្រោះថ្នាក់
- បានឃើញអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23 - 217 320

- បានឃើញប្រកាសលេខ៥៧១ ប្រក.កសក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីវិធានការការពារប្រភេទធនធានជលផលដែលកំពុងរងគ្រោះថ្នាក់
- យោងតាមសំណើរបស់ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងបង្កើតតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម ស្ថិតក្នុងភូមិសាស្ត្រសង្កាត់កោះរ៉ុង ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដើម្បីការពារ អភិរក្ស និងប្រើប្រាស់ធនធានជលផលសមុទ្រប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយវិស័យជលផលជាតិ និងរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅ៖

- បង្កើតបានតំបន់គ្រប់គ្រងជលផលសមុទ្រ
- គ្រប់គ្រងនិងអភិរក្សធនធានជីវចម្រុះជលផលសមុទ្រឲ្យមានប្រសិទ្ធភាព
- ធានាបានការនេសាទប្រកបដោយនិរន្តរភាព ដើម្បីលើកស្ទួយជីវភាពប្រជាពលរដ្ឋ
- រួមចំណែកអភិវឌ្ឍន៍វិស័យទេសចរណ៍ធម្មជាតិនិងការវិនិយោគនៅតំបន់កោះរ៉ុងនិងកោះរ៉ុងសន្លឹម។

**ប្រការ៣.-**

តំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹមរួមមាន តំបន់ផ្កាថ្ម តំបន់ថ្មប៉ប្រះទឹក តំបន់ស្មៅសមុទ្រ តំបន់ព្រៃកោងកាង តំបន់ទីជម្រកធនធានជលផលសំខាន់ផ្សេងៗទៀត និងប្រព័ន្ធអេកូឡូស៊ី ដែលមានសារៈសំខាន់សម្រាប់ជាជម្រកពងកូន រស់នៅ និងកន្លែងផ្តល់ចំណីដល់មច្ឆជាតិ និងវារិជាតដទៃទៀត។

**ប្រការ៤.-**

តំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម ស្ថិតនៅក្នុងដែននេសាទនៃភូមិសាស្ត្រសង្កាត់កោះរ៉ុង ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដែលមានផ្ទៃក្រឡាសរុប៤០ ៥៣៥ហិកតា (បួនម៉ឺនប្រាំរយសាមសិបប្រាំ) និងមាននិយាមកា (Datum WGS 84) ដូចខាងក្រោម៖

| ល.រ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|
| ១ | ២៩៧៨៥៧ | ១១៩២៨៤១ |
| ២ | ៣០៣២៨៥ | ១១៩៤៧៩៥ |
| ៣ | ៣០៨៦២៦ | ១១៩៦៦៩០ |
| ៤ | ៣១៤១១១ | ១១៩៣៨៤៧ |
| ៥ | ៣១៨៨៩៧ | ១១៩១៤៤៤ |
| ៦ | ៣១៩៦៣៨ | ១១៨៦៧៨៣ |
| ៧ | ៣២០៧១១ | ១១៧៧៨៣៨ |
| ៨ | ៣២១៥៩៨ | ១១៧០៦៨២ |

| | | |
|---|---|---|
| ៩ | ៣១៩៨១២ | ១១៦៣៨៥៨ |
| ១០ | ៣១៤០៣៧ | ១១៦៣៥៨៦ |
| ១១ | ៣០៦១២២ | ១១៧៤៦១១ |
| ១២ | ២៩៨២៨៤ | ១១៨៥៥៩៧ |

ផែនទីតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹមមានភ្ជាប់ជាឧបសម្ព័ន្ធ១ នៃប្រកាសនេះ។

**ប្រការ៥.-**

តំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម ត្រូវបានបែងចែកជា៦កន្លែង ដូចខាងក្រោម៖

១. **កន្លែងអភិរក្សជលផល** ត្រូវបានកំណត់ក្នុងភូមិសាស្ត្រដែលមានបណ្តុំផ្កាថ្ម ស្មៅសមុទ្រ ព្រៃកោងកាង ជម្រកធនធានជលផលដទៃទៀតដែលមានសក្តានុពលខ្ពស់ សម្រាប់វារិជាតពង កូន រីកធំធាត់ ឬរីកលូតលាស់។ កន្លែងអភិរក្សនេះមានចំនួន១៣កន្លែង និងមានផ្ទៃក្រឡាសរុប៦៦០ហិកតា មានទីតាំងស្ថិតនៅក្នុងដែននេសាទនៃភូមិព្រែកស្វាយចំនួន០៤កន្លែង ភូមិសុខសាន្តមានចំនួន០២កន្លែង ភូមិកោះតូចមានចំនួន០២កន្លែង ភូមិដើមថ្កូវមានចំនួន០២ កន្លែង និងភូមិកោះរ៉ុងសន្លឹមមានចំនួន០៣ កន្លែង។

២. **កន្លែងការពារធនធានជលផល** ត្រូវបានកំណត់ចំនួន០១កន្លែង ស្ថិតនៅក្នុងដែននេសាទនៃភូមិសុខសាន្ត ផ្នែកខាងលិចកោះរ៉ុង មានផ្ទៃក្រឡាសរុប៤១៣២ហិកតា។ កន្លែងនេះជាប់នឹងកន្លែងអភិរក្សជលផលដែលមាន បណ្តុំផ្កាថ្ម ស្មៅសមុទ្រ និងជម្រកធនធានជលផលដទៃទៀតជាបង្គួរ ហើយជួយគាំទ្រដល់កន្លែងអភិរក្សជលផល។

៣. **កន្លែងនេសាទសហគមន៍** មានចំនួន០៣កន្លែង គឺនៅសហគមន៍នេសាទភូមិព្រែកស្វាយ សហគមន៍នេសាទភូមិដើមថ្កូវ និងសហគមន៍នេសាទភូមិកោះរ៉ុងសន្លឹម ដែលមានផ្ទៃក្រឡាសរុប១៦ ៤២៩ហិកតា ហើយបានចុះបញ្ជីទទួលស្គាល់ជាផ្លូវការនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

៤. **ដែនជម្រកសុវត្ថិភាពជលផល** ត្រូវបានកំណត់ចំនួន០៤កន្លែង មានផ្ទៃក្រឡាសរុប១២៩ហិកតា ដែលមានទីតាំងស្ថិតនៅក្នុងដែននេសាទនៃភូមិដើមថ្កូវចំនួន០២កន្លែង ភូមិកោះតូចចំនួន០១កន្លែង និងភូមិកោះរ៉ុងសន្លឹមចំនួន០១កន្លែង។ តំបន់នេះមានមុខងារសម្រាប់ការពារពពួកត្រីអង្រែ ត្រីកាឡាំង និងក្តាមថ្ម ក្នុងដំណាក់កាលពងកូន។

៥. **កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ** ត្រូវបានកំណត់ចំនួន១៣កន្លែង មានផ្ទៃក្រឡាសរុប៤៥៤ហិកតា ដែលមានទីតាំងនៅក្នុងដែននេសាទនៃភូមិព្រែកស្វាយចំនួន០៤កន្លែង ភូមិសុខសាន្តចំនួន០២កន្លែង ភូមិកោះតូចចំនួន០២កន្លែង ភូមិដើមថ្កូវចំនួន០១កន្លែង និងភូមិកោះរ៉ុងសន្លឹមចំនួន០៤កន្លែង។ តំបន់នេះមាន មុខងារសម្រាប់បម្រើឲ្យសកម្មភាពកំសាន្ត សិក្សាស្រាវជ្រាវ និងកែលម្អទីជម្រកជលផល។

៦. **កន្លែងប្រើប្រាស់ច្រើនយ៉ាង** ត្រូវបានកំណត់ចំនួន១៣កន្លែង និងមានផ្ទៃក្រឡាសរុប១៨ ៧២៨ហិកតា ដែលមានទីតាំងនៅក្នុងដែននេសាទនៃភូមិព្រែកស្វាយចំនួន០៣កន្លែង ភូមិសុខសាន្តចំនួន០២កន្លែង ភូមិកោះតូចចំនួន០១កន្លែង ភូមិដើមថ្កូវចំនួន០២កន្លែង ភូមិកោះរ៉ុងសន្លឹមចំនួន០៤កន្លែង និងទីតាំងព័ទ្ធជុំវិញតំបន់គ្រប់គ្រងជលផលសមុទ្រប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម។តំបន់នេះមានមុខងារសម្រាប់បម្រើឲ្យសកម្មភាពនេសាទជាលក្ខណៈគ្រួសារនិងការអភិវឌ្ឍប្រកបដោយចីរភាព។ ៥៤

ផែនទីនិងនិយាមកា និយមន័យបែងចែកកន្លែងនីមួយៗ និងទីតាំងកន្លែងគ្រប់គ្រងលម្អិត ក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម ខេត្តព្រះសីហនុ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ២ ឧបសម្ព័ន្ធ៣ និងឧបសម្ព័ន្ធ៤ នៃប្រកាសនេះ។

**ប្រការ៦.-**

ហាមឃាត់ដាច់ខាតការធ្វើនេសាទដោយឧបករណ៍អួនអូស ឬឧបករណ៍នេសាទហាមឃាត់ផ្សេងទៀត នៅក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម លើកលែងតែការនេសាទដោយប្រើឧបករណ៍នេសាទស្របច្បាប់ជាលក្ខណៈគ្រួសារ ដែលអាចអនុញ្ញាតឲ្យធ្វើក្នុងកន្លែងនេសាទសហគមន៍ កន្លែងការពារ និងកន្លែងប្រើប្រាស់ច្រើនយ៉ាង។

**ប្រការ៧.-**

ការគ្រប់គ្រងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹមដូចមានចែងក្នុងប្រការ៥ខាងលើជាសមត្ថកិច្ចរបស់រដ្ឋបាលជលផល ដោយមានភារកិច្ចសំខាន់ៗដូចខាងក្រោម៖

- រៀបចំបង្កើតក្រុមការងារបច្ចេកទេសទទួលខុសត្រូវលើតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម
- រៀបចំនិងអនុវត្តផែនការគ្រប់គ្រងនិងបទបញ្ញាដែលពាក់ព័ន្ធ
- បោះបង្គោលឬពោងនៅកន្លែងអភិរក្សនិងដែនជម្រកសុវត្ថិភាពជលផល
- រៀបចំយន្តការអធិការកិច្ចនិងរៀបចំក្រុមល្បាតយាមប្រចាំការនៅតាមកន្លែងអភិរក្សជលផល និងទីតាំងសំខាន់ៗដើម្បីទប់ស្កាត់ជាបន្ទាន់នូវសកម្មភាពបទល្មើសនេសាទនិងសកម្មភាពផ្សេងៗទៀតដែលប៉ះពាល់ដល់ធនធានជលផល
- បង្កើតហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការងារគ្រប់គ្រងដូចជា ស្នាក់ការត្រួតពិនិត្យ ស្នាក់ការស្រាវជ្រាវ និងមធ្យោបាយត្រួតពិនិត្យ
- លើកកម្ពស់ជីវភាពរស់នៅដល់សហគមន៍មូលដ្ឋានឲ្យប្រសើរឡើងតាមរយៈការប្រើប្រាស់ធនធានធម្មជាតិ ការបង្កើតមុខរបរបន្ថែម ការធ្វើនេសាទ និងសេវាកម្មទេសចរណ៍ធម្មជាតិ
- សិក្សាស្រាវជ្រាវបច្ចេកទេស អង្កេត តាមដានលក្ខណៈជីវសាស្ត្រ សេដ្ឋកិច្ចសង្គម និងអភិបាលកិច្ច ដើម្បីត្រួតពិនិត្យលើប្រសិទ្ធភាពតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម
- អប់រំនិងផ្សព្វផ្សាយអំពីច្បាប់ស្ដីពីជលផល លិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ និងសារៈសំខាន់នៃជីវចម្រុះក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម
- ដោះស្រាយទំនាស់ឬបញ្ហាពាក់ព័ន្ធនឹងវិស័យជលផលដែលកើតមានក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម
- សហការជាមួយស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងសប្បុរសជននានា ដើម្បីគាំទ្រសកម្មភាពគ្រប់គ្រងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម
- ស្វែងរកនិងគ្រប់គ្រងមូលនិធិសម្រាប់ប្រតិបត្តិការក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម។

**ប្រការ៨.-**

ថវិកាសម្រាប់ការងារបង្កើតនិងគ្រប់គ្រងតំបន់គ្រប់គ្រងជលផលនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹមនេះ ត្រូវបានពីប្រភពផ្សេងៗ ជាអាទិ៍៖

- ថវិការបស់រាជរដ្ឋាភិបាល
- ជំនួយពីដៃគូអភិវឌ្ឍន៍នានានិងស្ថាប័នផ្តល់ជំនួយផ្សេងៗ
- ជំនួយពីវិស័យឯកជន
- អំណោយពីសប្បុរសជន និង
- ចំណូលស្របច្បាប់ផ្សេងៗទៀត។

**ប្រការ៩.-**

ជនណាដែលប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

**ប្រការ១០.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១១.-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលជលផល ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និង ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលាខេត្តព្រះសីហនុ
- ដូចប្រការ១១
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធ១ ផែនទីកំណត់តំបន់គ្រប់គ្រងជលផលសមុទ្រ នៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម




| Post | X | Y |
|---|---|---|
| 1 | 297857 | 1192841 |
| 2 | 303285 | 1194795 |
| 3 | 308626 | 1196690 |
| 4 | 314111 | 1193847 |
| 5 | 318897 | 1191444 |
| 6 | 319638 | 1186783 |
| 7 | 320711 | 1177838 |
| 8 | 321598 | 1170682 |
| 9 | 319812 | 1163658 |
| 10 | 314037 | 1163586 |
| 11 | 306122 | 1174611 |
| 12 | 298284 | 1185597 |

Map ID: FFI-CMCP-6-00111, Date:14-8-2014 Datum WGS 84

# ឧបសម្ព័ន្ធ២ ផែនទីបែងចែកតំបន់គ្រប់គ្រងជលផលសមុទ្រ នៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម




| Post | X | Y |
|---|---|---|
| 1 | 297857 | 1192841 |
| 2 | 303285 | 1194795 |
| 3 | 308626 | 1196690 |
| 4 | 314111 | 1193847 |
| 5 | 318897 | 1191444 |
| 6 | 319638 | 1186783 |
| 7 | 320711 | 1177838 |
| 8 | 321598 | 1170682 |
| 9 | 319812 | 1163658 |
| 10 | 314037 | 1163586 |
| 11 | 306122 | 1174611 |
| 12 | 298284 | 1185597 |

Map ID: FFI-CMCP-6-00110, Date:14-08-2014 Map Datum WGS 84

## ឧបសម្ព័ន្ធទី ៣៖ និយមន័យបែងចែកកន្លែងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុង និងកោះរ៉ុងសន្លឹម

**កន្លែងអភិរក្សជលផល:** ត្រូវបានកំណត់ក្នុងភូមិសាស្ត្រដែលមានសក្តានុពលជាក់លាក់សម្រាប់វារីសត្វឬរុក្ខជាតិ ជ្រកពួន ពង កូន រីកធំធាត់ ឬរីកលូតលាស់។ កន្លែងអភិរក្សជលផល ពុំអាចអនុញ្ញាតឲ្យប្រព្រឹត្តសកម្មភាពដែលនាំឲ្យមានផលប៉ះពាល់ដល់ធនធានជលផលបានឡើយ ក្រៅពីការស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ដោយមានការអនុញ្ញាតពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**កន្លែងការពារធនធានជលផល:** ត្រូវបានកំណត់នៅទីតាំងជាប់ឬក្បែរកន្លែងអភិរក្សជលផលដែលមានមុខងារជាសំខាន់ជួយគាំទ្រដល់កន្លែងអភិរក្សជលផល ដើម្បីធានានិរន្តរភាពធនធានជលផល។ កន្លែងការពារនេះ អាចប្រើប្រាស់ជាកន្លែងបំរើឲ្យវិស័យទេសចរណ៍ធម្មជាតិ ការនេសាទជាលក្ខណៈកំសាន្តឬជាលក្ខណៈគ្រួសារ ដែលមិនមានការបំផ្លិចបំផ្លាញដល់ធនធានជលផលនិងជីវចម្រុះឡើយ។

**កន្លែងនេសាទសហគមន៍**: ជាដែននេសាទរបស់រដ្ឋដែលបានប្រគល់ជូនសហគមន៍ក្រោមកិច្ចព្រមព្រៀងរវាងនាយខណ្ឌរដ្ឋបាលជលផលជាមួយសហគមន៍ឬក្រុមប្រជាពលរដ្ឋរស់នៅក្នុងឬក្បែរដែននេសាទដែលពឹងផ្អែកលើការធ្វើនេសាទសម្រាប់ការចិញ្ចឹមជីវិតនិងការប្រើប្រាស់ជាប្រពៃណី ហើយដែលធ្វើការគ្រប់គ្រងឬប្រើប្រាស់កន្លែងនេសាទនោះប្រកបដោយនិរន្តរភាព។ ការនេសាទក្នុងកន្លែងនេសាទសហគមន៍អាចប្រព្រឹត្តទៅបានគ្រប់រដូវកាលនិងប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ។ ការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវអនុវត្តទៅតាមបទប្បញ្ញត្តិគតិយុត្តពាក់ព័ន្ធនឹងសហគមន៍នេសាទជាធរមាន។

**ដែនជម្រកសុវត្ថិភាពជលផល:** ត្រូវកំណត់ក្នុងភូមិសាស្ត្រជាក់លាក់សម្រាប់ការពារប្រភេទវារីសត្វមួយឬច្រើនក្នុងដំណាក់កាលនៃវដ្តជីវិតពិសេសរបស់វារីសត្វ។ ការធ្វើនេសាទឬសកម្មភាពផ្សេងៗនៅក្នុងដែនជម្រកសុវត្ថិភាពជលផលត្រូវបានហាមឃាត់ក្នុងរដូវកាលជាក់លាក់ ហើយក្រោយរដូវកាលនេះ ការនេសាទជាលក្ខណៈគ្រួសារនិងសកម្មភាពផ្សេងៗទៀតដែលពុំប៉ះពាល់ជាអវិជ្ជមានដល់ធនធានជលផលអាចអនុញ្ញាតបានជាធម្មតា។

**កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ:** ត្រូវបានកំណត់ថាជាតំបន់ដែលមានមុខងារសំខាន់សម្រាប់បំរើឲ្យសកម្មភាពកំសាន្តនិងការពារប្រភពធនធានជីវចម្រុះ ដើម្បីធានាបានប្រាក់ចំណូលពីវិស័យទេសចរណ៍បាតសមុទ្រនិងនិរន្តរភាពធនធានជលផល។ កន្លែងនេះត្រូវបានអនុញ្ញាតសម្រាប់ការមុជទឹកកំសាន្តមើលផ្កាថ្មនិងធនធានជលផលដទៃទៀតប្រកបដោយការទទួលខុសត្រូវ ព្រមទាំងសម្រាប់ការប្រមូលព័ត៌មានវិទ្យាសាស្ត្រនិងតាមដានបម្រែបម្រួលធនធានជលផល។ ការនេសាទគ្រប់ប្រភេទនៅក្នុងកន្លែងនេះត្រូវបានហាមឃាត់។

**កន្លែងប្រើប្រាស់ច្រើនយ៉ាង:** ត្រូវបានកំណត់នៅខាងក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រដែលមិនមានវត្តមានប្រភេទធនធានជលផលសំខាន់ៗនិងរងគ្រោះថ្នាក់។ កន្លែងនេះអាចអនុញ្ញាតឲ្យមានសកម្មភាពចម្រុះផ្សេងៗ ដែលមិនប៉ះពាល់ធ្ងន់ធ្ងរដល់ធនធានជលផល ព្រមទាំងអនុញ្ញាតឲ្យធ្វើនេសាទជាលក្ខណៈគ្រួសារ។

**ឧបសម្ព័ន្ធ៤៖ តារាងបែងចែកកន្លែងគ្រប់គ្រងលំអិតក្នុងតំបន់គ្រប់គ្រងជលផលសមុទ្រនៅប្រជុំកោះរ៉ុងនិងកោះរ៉ុងសន្លឹម សង្កាត់កោះរ៉ុង ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ**

| ល.រ | លេខកូដ | ប្រភេទកន្លែងជលផល | ទំហំ (ហត) | ឈ្មោះភូមិ | អាប់ស៊ីស | អ័រដោនេ |
|---|---|---|---|---|---|---|
| 1 | 1 | កន្លែងអភិរក្សជលផល | 25 | ដើមថ្កូវ | 314153 | 1184787 |
| | | | | | 314136 | 1184291 |
| | | | | | 313629 | 1184296 |
| | | | | | 313697 | 1184558 |
| | | | | | 313462 | 1184746 |
| 2 | 13 | កន្លែងអភិរក្សជលផល | 64 | ដើមថ្កូវ | 314560 | 1184160 |
| | | | | | 314700 | 1184121 |
| | | | | | 314710 | 1183897 |
| | | | | | 314391 | 1183488 |
| | | | | | 314103 | 1183280 |
| | | | | | 313572 | 1183414 |
| | | | | | 313629 | 1183637 |
| | | | | | 314322 | 1183962 |
| | | | | | 313485 | 1183954 |
| 3 | 2 | កន្លែងអភិរក្សជលផល | 54 | ព្រែកស្វាយ | 310165 | 1187804 |
| | | | | | 310167 | 1187090 |
| | | | | | 309357 | 1187087 |
| | | | | | 309560 | 1187803 |
| | | | | | 309360 | 1187560 |
| | | | | | 309517 | 1187659 |
| 4 | 47 | កន្លែងអភិរក្សជលផល | 2 | ព្រែកស្វាយ | 307967 | 1190775 |
| | | | | | 307770 | 1190707 |
| | | | | | 307985 | 1190590 |
| | | | | | 308035 | 1190634 |
| | | | | | 307875 | 1190720 |
| 5 | 46 | កន្លែងអភិរក្សជលផល | 3 | ព្រែកស្វាយ | 307777 | 1190435 |
| | | | | | 307668 | 1190611 |
| | | | | | 307605 | 1190451 |
| | | | | | 307718 | 1190349 |
| 6 | 19 | កន្លែងអភិរក្សជលផល | 120 | ព្រែកស្វាយ | 302235 | 1189570 |
| | | | | | 301901 | 1189566 |
| | | | | | 301784 | 1188322 |
| | | | | | 301177 | 1187521 |
| | | | | | 302075 | 1187284 |
| | | | | | 302111 | 1186840 |
| | | | | | 301160 | 1186973 |
| | | | | | 300930 | 1187724 |
| | | | | | 301527 | 1188509 |
| 7 | 45 | កន្លែងអភិរក្សជលផល | 100 | សុខសាន្ត | 303370 | 1185495 |
| | | | | | 303021 | 1185489 |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | 303482 | 1184541 |
| | | | | | 303679 | 1184779 |
| | | | | | 304475 | 1183595 |
| | | | | | 304504 | 1183896 |
| | | | | | 305384 | 1183603 |
| | | | | | 305333 | 1183306 |
| 8 | 20 | កន្លែងអភិរក្សជលផល | 53 | សុខសាន្ត | 309261 | 1178920 |
| | | | | | 309557 | 1178969 |
| | | | | | 309805 | 1178272 |
| | | | | | 309576 | 1178078 |
| | | | | | 310468 | 1177732 |
| | | | | | 310449 | 1178040 |
| 9 | 8 | កន្លែងអភិរក្សជលផល | 33 | កោះតូច | 314048 | 1181441 |
| | | | | | 314253 | 1181299 |
| | | | | | 314171 | 1180770 |
| | | | | | 313792 | 1180552 |
| | | | | | 313599 | 1180628 |
| | | | | | 313602 | 1180966 |
| | | | | | 313889 | 1181088 |
| 10 | 43 | កន្លែងអភិរក្សជលផល | 24 | កោះតូច | 313193 | 1180411 |
| | | | | | 313504 | 1180153 |
| | | | | | 313441 | 1179770 |
| | | | | | 313407 | 1179571 |
| | | | | | 313103 | 1179603 |
| | | | | | 313223 | 1180050 |
| | | | | | 313137 | 1179901 |
| | | | | | 313155 | 1180113 |
| 11 | 15 | កន្លែងអភិរក្សជលផល | 30 | កោះរ៉ុងសន្លឹម | 313862 | 1176074 |
| | | | | | 313630 | 1176572 |
| | | | | | 314211 | 1176786 |
| | | | | | 314294 | 1176227 |
| | | | | | 313930 | 1176692 |
| | | | | | 314069 | 1176162 |
| 12 | 7 | កន្លែងអភិរក្សជលផល | 115 | កោះរ៉ុងសន្លឹម | 312062 | 1173764 |
| | | | | | 311748 | 1173951 |
| | | | | | 311762 | 1172884 |
| | | | | | 311472 | 1172821 |
| | | | | | 312072 | 1171589 |
| | | | | | 311788 | 1171497 |
| | | | | | 312517 | 1170426 |
| | | | | | 312366 | 1170169 |
| 13 | 17 | កន្លែងអភិរក្សជលផល | 37 | កោះរ៉ុងសន្លឹម | 316008 | 1165544 |
| | | | | | 315984 | 1165843 |
| | | | | | 316675 | 1165645 |
| | | | | | 316568 | 1165948 |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | 316769 | 1166174 |
| | | | | | 317078 | 1166162 |
| | | សរុប | 660 | | | |
| 14 | 10 | ដែនជម្រកសុវត្ថិភាពជលផល | 23 | ដើមថ្កូវ | 313487 | 1184114 |
| | | | | | 313212 | 1184223 |
| | | | | | 313126 | 1183942 |
| | | | | | 313285 | 1183608 |
| | | | | | 313601 | 1183533 |
| | | | | | 313524 | 1183747 |
| 15 | 14 | ដែនជម្រកសុវត្ថិភាពជលផល | 25 | ដើមថ្កូវ | 315376 | 1184846 |
| | | | | | 315801 | 1184625 |
| | | | | | 316148 | 1184194 |
| | | | | | 315824 | 1184189 |
| | | | | | 315608 | 1184434 |
| | | | | | 315264 | 1184594 |
| 16 | 12 | ដែនជម្រកសុវត្ថិភាពជលផល | 28 | កោះតូច | 312993 | 1180663 |
| | | | | | 312808 | 1180833 |
| | | | | | 312231 | 1179753 |
| | | | | | 312058 | 1179870 |
| 17 | 40 | ដែនជម្រកសុវត្ថិភាពជលផល | 53 | កោះរ៉ុងសន្លឹម | 313023 | 1175499 |
| | | | | | 313617 | 1175430 |
| | | | | | 313250 | 1176079 |
| | | | | | 313862 | 1176074 |
| | | | | | 313630 | 1176572 |
| | | សរុប | 129 | | | |
| 18 | 24 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 25 | ដើមថ្កូវ | 315982 | 1183914 |
| | | | | | 315819 | 1183730 |
| | | | | | 316049 | 1183358 |
| | | | | | 315769 | 1183310 |
| | | | | | 315520 | 1183673 |
| | | | | | 315745 | 1184123 |
| 19 | 23 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 21 | ដើមថ្កូវ | 309830 | 1185898 |
| | | | | | 310194 | 1185895 |
| | | | | | 310230 | 1186281 |
| | | | | | 309877 | 1186588 |
| | | | | | 309790 | 1186314 |
| | | | | | 309900 | 1186105 |
| 20 | 34 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 30 | ព្រែកស្វាយ | 306393 | 1191730 |
| | | | | | 306545 | 1191745 |
| | | | | | 306288 | 1191167 |
| | | | | | 305746 | 1190783 |
| | | | | | 304906 | 1190527 |
| | | | | | 304884 | 1190604 |
| | | | | | 305486 | 1190735 |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | 305838 | 1191018 |
| 21 | 41 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 34 | សុខសាន្ត | 306539 | 1184195 |
| | | | | | 306372 | 1184277 |
| | | | | | 306974 | 1184385 |
| | | | | | 307815 | 1184101 |
| | | | | | 308345 | 1183531 |
| | | | | | 308194 | 1183429 |
| | | | | | 307709 | 1183994 |
| | | | | | 307090 | 1184229 |
| 22 | 21 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 53 | សុខសាន្ត | 308518 | 1183302 |
| | | | | | 308377 | 1183178 |
| | | | | | 308943 | 1182401 |
| | | | | | 308809 | 1182331 |
| | | | | | 309196 | 1181179 |
| | | | | | 309345 | 1181203 |
| | | | | | 309389 | 1179945 |
| | | | | | 309248 | 1179951 |
| 23 | 22 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 49 | សុខសាន្ត | 302293 | 1187405 |
| | | | | | 302280 | 1187579 |
| | | | | | 302352 | 1187683 |
| | | | | | 302587 | 1187678 |
| | | | | | 302729 | 1187634 |
| | | | | | 302829 | 1187469 |
| | | | | | 303016 | 1187543 |
| | | | | | 303258 | 1187376 |
| | | | | | 303472 | 1187034 |
| | | | | | 303463 | 1186711 |
| | | | | | 303340 | 1186729 |
| | | | | | 302973 | 1186722 |
| | | | | | 303128 | 1186955 |
| | | | | | 303150 | 1187057 |
| | | | | | 302876 | 1187220 |
| | | | | | 302581 | 1187322 |
| 24 | 25 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 53 | កោះតូច | 311119 | 1179415 |
| | | | | | 311278 | 1179392 |
| | | | | | 311568 | 1180005 |
| | | | | | 311682 | 1179900 |
| | | | | | 311758 | 1180729 |
| | | | | | 311909 | 1180679 |
| | | | | | 311967 | 1180927 |
| | | | | | 312031 | 1180994 |
| | | | | | 313390 | 1181248 |
| | | | | | 313301 | 1181127 |
| | | | | | 312586 | 1181320 |
| | | | | | 312521 | 1181144 |

| | | | | | | |
|---|---|---|---|---|---|---|
| 25 | 42 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 22 | កោះរ៉ុងសន្លឹម | 313017 | 1169579 |
| | | | | | 313262 | 1169780 |
| | | | | | 313477 | 1169730 |
| | | | | | 313622 | 1169185 |
| | | | | | 313561 | 1169127 |
| | | | | | 313257 | 1169191 |
| | | | | | 313301 | 1169428 |
| 26 | 28 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 57 | កោះរ៉ុងសន្លឹម | 316346 | 1169112 |
| | | | | | 316366 | 1169314 |
| | | | | | 315262 | 1169600 |
| | | | | | 315414 | 1169738 |
| | | | | | 314711 | 1170146 |
| | | | | | 314890 | 1170239 |
| | | | | | 314505 | 1170614 |
| | | | | | 314622 | 1170933 |
| | | | | | 314841 | 1170927 |
| | | | | | 314978 | 1170767 |
| | | | | | 314748 | 1170542 |
| 27 | 27 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 32 | កោះរ៉ុងសន្លឹម | 316349 | 1173523 |
| | | | | | 316099 | 1174153 |
| | | | | | 315944 | 1174542 |
| | | | | | 315704 | 1174365 |
| | | | | | 315805 | 1173989 |
| | | | | | 316087 | 1173550 |
| 28 | 26 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 39 | កោះរ៉ុងសន្លឹម | 314679 | 1174671 |
| | | | | | 314917 | 1174521 |
| | | | | | 314480 | 1174136 |
| | | | | | 313680 | 1174391 |
| | | | | | 313887 | 1174609 |
| | | | | | 314220 | 1174386 |
| 29 | 18 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 18,313 | ជុំវិញកោះរ៉ុង និងកោះរ៉ុងសន្លឹម | 297857 | 1192841 |
| | | | | | 303285 | 1194795 |
| | | | | | 308626 | 1196690 |
| | | | | | 314111 | 1193847 |
| | | | | | 318897 | 1191444 |
| | | | | | 319638 | 1186783 |
| | | | | | 320711 | 1177838 |
| | | | | | 321598 | 1170682 |
| | | | | | 319812 | 1163658 |
| | | | | | 314037 | 1163586 |
| | | | | | 306122 | 1174611 |
| | | | | | 298284 | 1185597 |
| 30 | 33 | កន្លែងប្រើប្រាស់ច្រើនយ៉ាង | 2 | ព្រែកស្វាយ | 303683 | 1185712 |
| | | | | | 303493 | 1185577 |

| | | | | | | |
|---|---|---|---|---|---|---|
| | | សរុប | 18,730 | | | |
| 31 | 4 | កន្លែងការពារផលផល | 4,132 | សុខសាន្ត | 300065 | 1185483 |
| | | | | | 301872 | 1185490 |
| | | | | | 304591 | 1179351 |
| | | | | | 303105 | 1184882 |
| | | | | | 304928 | 1183391 |
| | | | | | 306443 | 1183574 |
| | | | | | 307904 | 1183827 |
| | | | | | 308949 | 1181968 |
| | | | | | 309388 | 1180428 |
| | | | | | 309842 | 1177797 |
| | | | | | 310669 | 1178204 |
| | | | | | 310805 | 1175341 |
| | | | | | 310802 | 1177121 |
| | | សរុប | 4,132 | | | |
| 32 | 35 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 15 | ដើមថ្កូវ | 310805 | 1185736 |
| | | | | | 310561 | 1185315 |
| | | | | | 310353 | 1185019 |
| | | | | | 309987 | 1184820 |
| | | | | | 309973 | 1185002 |
| | | | | | 310171 | 1184989 |
| | | | | | 310059 | 1185147 |
| | | | | | 310274 | 1185143 |
| | | | | | 310395 | 1185328 |
| | | | | | 310520 | 1185405 |
| | | | | | 310697 | 1185580 |
| 33 | 29 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 35 | ព្រែកស្វាយ | 309865 | 1189889 |
| | | | | | 310270 | 1190182 |
| | | | | | 310485 | 1189851 |
| | | | | | 310255 | 1189589 |
| | | | | | 310140 | 1189404 |
| | | | | | 309848 | 1189269 |
| | | | | | 309692 | 1189481 |
| | | | | | 309926 | 1189462 |
| | | | | | 310053 | 1189594 |
| | | | | | 310021 | 1189729 |
| 34 | 32 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 8 | ព្រែកស្វាយ | 302293 | 1187405 |
| | | | | | 303023 | 1187170 |
| | | | | | 302972 | 1186720 |
| | | | | | 303169 | 1186720 |
| | | | | | 303460 | 1186686 |
| | | | | | 303476 | 1187062 |
| | | | | | 303050 | 1187520 |
| | | | | | 302352 | 1187683 |

| | | | | | | |
|---|---|---|---|---|---|---|
| 35 | 11 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 6 | ព្រែកស្វាយ | 302733 | 1187518 |
| | | | | | 302955 | 1187594 |
| | | | | | 302765 | 1187585 |
| | | | | | 303038 | 1187765 |
| | | | | | 303474 | 1187723 |
| | | | | | 303429 | 1187647 |
| | | | | | 303050 | 1187703 |
| 36 | 16 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 36 | ព្រែកស្វាយ | 303052 | 1186721 |
| | | | | | 303392 | 1186707 |
| | | | | | 303062 | 1186121 |
| | | | | | 303400 | 1186084 |
| | | | | | 303613 | 1185803 |
| | | | | | 303548 | 1185633 |
| | | | | | 303511 | 1185734 |
| | | | | | 303370 | 1185495 |
| | | | | | 303021 | 1185489 |
| | | | | | 303370 | 1185818 |
| | | | | | 302969 | 1186433 |
| | | | | | 303253 | 1186456 |
| 37 | 38 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 43 | សុខសាន្ត | 305333 | 1183306 |
| | | | | | 305384 | 1183603 |
| | | | | | 306029 | 1183570 |
| | | | | | 306158 | 1183294 |
| | | | | | 306659 | 1183881 |
| | | | | | 306382 | 1183995 |
| 38 | 39 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 21 | សុខសាន្ត | 309181 | 1179634 |
| | | | | | 309469 | 1179655 |
| | | | | | 309261 | 1178920 |
| | | | | | 309557 | 1178969 |
| | | | | | 309497 | 1179314 |
| 39 | 3 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 7 | កោះតូច | 311967 | 1180927 |
| | | | | | 312031 | 1180994 |
| | | | | | 311837 | 1180878 |
| | | | | | 311870 | 1181087 |
| | | | | | 311796 | 1180943 |
| | | | | | 312131 | 1181153 |
| | | | | | 312084 | 1181347 |
| | | | | | 312118 | 1181682 |
| | | | | | 312145 | 1181430 |
| 40 | 36 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 49 | កោះតូច | 313343 | 1179193 |
| | | | | | 313407 | 1179571 |
| | | | | | 313103 | 1179603 |
| | | | | | 313137 | 1179901 |
| | | | | | 313092 | 1179927 |
| | | | | | 313155 | 1180113 |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | 313193 | 1180411 |
| | | | | | 312909 | 1180285 |
| | | | | | 312792 | 1179916 |
| | | | | | 312718 | 1179285 |
| 41 | 37 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 117 | កោះរ៉ុងសន្លឹម | 314294 | 1176227 |
| | | | | | 314211 | 1176786 |
| | | | | | 315201 | 1176904 |
| | | | | | 314458 | 1176058 |
| | | | | | 314583 | 1175715 |
| | | | | | 315728 | 1175951 |
| | | | | | 315438 | 1176478 |
| | | | | | 315080 | 1175817 |
| | | | | | 314673 | 1176841 |
| 42 | 5 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 33 | កោះរ៉ុងសន្លឹម | 312791 | 1174472 |
| | | | | | 312647 | 1174711 |
| | | | | | 312321 | 1174167 |
| | | | | | 312131 | 1174340 |
| | | | | | 312062 | 1173764 |
| | | | | | 311748 | 1173951 |
| 43 | 31 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 45 | កោះរ៉ុងសន្លឹម | 313561 | 1169127 |
| | | | | | 313257 | 1169191 |
| | | | | | 313444 | 1168571 |
| | | | | | 313901 | 1168641 |
| | | | | | 314021 | 1168363 |
| | | | | | 313359 | 1168225 |
| | | | | | 313104 | 1168709 |
| 44 | 30 | កន្លែងមុជទឹកកំសាន្តបាតសមុទ្រនិងសិក្សាស្រាវជ្រាវ | 39 | កោះរ៉ុងសន្លឹម | 314843 | 1166321 |
| | | | | | 315152 | 1166324 |
| | | | | | 315498 | 1165945 |
| | | | | | 315984 | 1165843 |
| | | | | | 316008 | 1165544 |
| | | | | | 315224 | 1165767 |
| | | សរុប | 454 | | | |
| 45 | 6 | កន្លែងនេសាទសហគមន៍ | 7,011 | ព្រែកស្វាយ | 307995 | 1194748 |
| | | | | | 300031 | 1191992 |
| | | | | | 316003 | 1190363 |
| | | | | | 300485 | 1185146 |
| | | | | | 303955 | 1185165 |
| | | | | | 309090 | 1186759 |
| | | | | | 316099 | 1188732 |
| 46 | 9 | កន្លែងនេសាទសហគមន៍ | 1,493 | ដើមថ្កូវ | 310314 | 1185796 |
| | | | | | 310812 | 1184875 |
| | | | | | 311316 | 1185599 |
| | | | | | 312674 | 1185761 |

| | | | | | | |
|---|---|---|---|---|---|---|
| | | | | | 314113 | 1184304 |
| | | | | | 314010 | 1183153 |
| | | | | | 315509 | 1184407 |
| | | | | | 316212 | 1183928 |
| | | | | | 31098 | 1182662 |
| | | | | | 318101 | 1182652 |
| | | | | | 316098 | 1186734 |
| | | | | | 309089 | 1186761 |
| 47 | 44 | កន្លែងនេសាទសហគមន៍ | 7,925 | កោះរ៉ុងសន្លឹម | 317785 | 1174747 |
| | | | | | 319071 | 1172602 |
| | | | | | 320403 | 1170511 |
| | | | | | 319249 | 1165609 |
| | | | | | 317249 | 1164625 |
| | | | | | 316394 | 1164441 |
| | | | | | 315796 | 1164583 |
| | | | | | 314796 | 1165583 |
| | | | | | 314587 | 1165990 |
| | | | | | 314665 | 1166504 |
| | | | | | 314017 | 1167485 |
| | | | | | 312892 | 1168053 |
| | | | | | 312755 | 1169314 |
| | | | | | 311612 | 1170429 |
| | | | | | 311097 | 1172864 |
| | | | | | 311227 | 1173363 |
| | | សរុប | 16,429 | | | |